# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ សសរ

## សេចក្ដីសម្រេច

### ស្ដីពី

### ការបង្កើតក្រុមការងារពិសេសដើម្បីសម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យកែសំរួលលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមការងារពិសេស ដើម្បីសម្របសម្រួល និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ ដែលមានសមាសភាព ដូចមានខាងក្រោម :

១- ឯកឧត្តម សុខ ចិន្តា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធាន

២- ឯកឧត្តម នុត ណារ៉ាង រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

៣- ឯកឧត្តម ប្រាជ្ញ ស៊ុន រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

៤- ឯកឧត្តម ភោគ សុវណ្ណរិទ្ធ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៥- ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

៦- ឯកឧត្ត លឹម ស៊ីដេនីន រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៧- ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៨- ឯកឧត្តម សួស យ៉ារ៉ា អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩- ឯកឧត្តម ស្បោង សារ៉ាត អភិបាលខេត្តព្រះសីហនុ សមាជិក

**ប្រការ២** : ក្រុមការងារពិសេសនេះ មានតួនាទី និងភារកិច្ចដូចតទៅ :

- ចុះពិនិត្យជាក់ស្តែង និងជំរុញដោះស្រាយរាល់បញ្ហាដែលក្រុមហ៊ុនវិនិយោគជួបប្រទះក្នុងដំណើរការគំរោងអភិវឌ្ឍន៍កោះពស់ និងផ្នែកនៃតំបន់ឆ្នេរហាវ៉ៃ សំដៅសម្រួលការអភិវឌ្ឍន៍គំរោងនេះអោយដំណើរការទៅបានដោយរលូន និងមានប្រសិទ្ធភាព
- ធ្វើរបាយការណ៍ និងលើកសំណើសុំយោបល់ និងការសំរេចផ្ទាល់ជូនប្រមុខរាជរដ្ឋាភិបាល លើរាល់ករណីពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាដែលក្រុមហ៊ុនជួបប្រទះ ។

**ប្រការ៣** : សមាជិកនៃក្រុមការងារពិសេស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ប្រធានក្រុមការងារមានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមផ្តល់មតិ និងដោះស្រាយបញ្ហា ។ ក្រុមការងារពិសេសមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ដំណើរការការងាររបស់ខ្លួន ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសមាសភាព ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ